ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៥៣ ប្រក.កសក.ម

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ៤ នៃប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីរពិសោធន៍ ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia. Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីរពិសោធន៍ ចំណុះនាយកដ្ឋាន និងវិទ្យាស្ថាន ក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ៦០៩ ប្រក កញ្ញា ឆ្នាំ២០១៦ កសក ចុះថ្ងៃទី២៧.ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្មរាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឲ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងលិខិតលេខ១៣១១ មស.នក ចុះថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈស្តីពីការឯកភាពក្នុងការបង្កើតការិយាល័យគ្រប់គ្រងជំងឺ និងសុខភាពវារីសត្វ ចំណុះនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការមួយ._**

ប្រការ៤ នៃប្រកាសលេខ៦៨១ ប្រក.កសក.បុ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីរពិសោធន៍ ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល ត្រូវបានធ្វើការកែសម្រួលដូចតទៅ ៖

**ប្រការ៤._ ថ្មី**

នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល មានការិយាល័យចំណុះចំនួន០៥ ដូចខាងក្រោមគឺ៖

១- ការិយាល័យរដ្ឋបាល និងផ្សព្វផ្សាយ

២- ការិយាល័យវារីវប្បកម្មទឹកសាប

៣- ការិយាល័យវារីវប្បកម្មសមុទ្រ

៤- ការិយាល័យស្រះជម្រកត្រីសហគមន៍

៥- ការិយាល័យគ្រប់គ្រងជំងឺ និងសុខភាពវារីសត្វ

តួនាទី ភារកិច្ច របស់ការិយាល័យនីមួយៗមានដូចតទៅ ៖

**៤.១. ការិយាល័យរដ្ឋបាល និងផ្សព្វផ្សាយ ៖**

- គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពការងារផ្នែករដ្ឋបាល និងបុគ្គលិករបស់នាយកដ្ឋាន
- រៀបចំប្រមូលទិន្នន័យវារីវប្បកម្ម និងសហគមន៍ស្រះជម្រកត្រី
- រៀបចំចងក្រង ផលិត បណ្តុះបណ្តាល និងផ្សព្វផ្សាយឯកសារបច្ចេកទេស
- រៀបចំផ្សព្វផ្សាយទីផ្សារចែកចាយកូនត្រីពូជ
- សិក្សាពីវិធីសាស្ត្រផ្សព្វផ្សាយ និងវាយតម្លៃពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

**៤.២. ការិយាល័យវារីវប្បកម្មទឹកសាប៖**

- រៀបចំផែនការសកម្មភាព និងលិខិតបទដ្ឋានសម្រាប់គ្រប់គ្រងសេនេទិច និងអភិវឌ្ឍវារីវប្បកម្មទឹកសាប

- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាវារីវប្បកម្មទឹកសាប ( ពូជ ចំណី គុណភាពទឹក ការការពារ ការព្យាបាល ) និងប្រភេទ ដែលអាចធ្វើវារីវប្បកម្មបាន
- រៀបចំឯកសារ និងបណ្តុះបណ្តាលបច្ចេកទេស និងការអភិវឌ្ឍទិន្នន័យគ្រប់គ្រងវារីវប្បកម្ម
- គ្រប់គ្រងសកម្មភាពវារីវប្បកម្ម និងលើកទឹកចិត្តដល់ការវិនិយោគវិស័យឯកជន ដើម្បីជំរុញដល់ការអភិវឌ្ឍវារីវប្បកម្មទឹកសាប
- គ្រប់គ្រងការនាំចូល នាំចេញវារីជាតទឹកសាប ឧបករណ៍ សម្ភារ ថ្នាំព្យាបាល និងសារធាតុគីមី ដែលពាក់ព័ន្ធ នឹងការងារអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប
- បង្កើនផលិតកម្មពូជប្រភេទវារីជាតជិតផុតពូជតាមរយៈការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសវារីវប្បកម្ម
- ពិនិត្យសំណុំបែបបទស្នើសុំធ្វើវារីវប្បកម្ម និងតាមដានការបញ្ចេញកាកសំណល់របស់កសិដ្ឋានវារីវប្បកម្ម
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

៤.៣. ការិយាល័យវារីវប្បកម្មសមុទ្រ៖

- សិក្សាកំណត់តំបន់ដែលមានសក្តានុពលសម្រាប់អភិវឌ្ឍវារីវប្បកម្មសមុទ្រនិងនៅតាមឆ្នេរ និងរៀបចំផែនការសកម្មភាព កសាងលិខិតបទដ្ឋានសម្រាប់គ្រប់គ្រង និងអភិវឌ្ឍរួមទាំងសេនេទិច និងជំងឺ
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាវារីវប្បកម្មវារីជាតសមុទ្រ (ពូជ ចំណី គុណភាពទឹក) និងប្រភេទដែលអាចធ្វើវារីវប្បកម្មបាន
- រៀបចំឯកសារ និងបណ្តុះបណ្តាលបច្ចេកទេស និងការគ្រប់គ្រងវារីវប្បកម្ម
- គ្រប់គ្រងសកម្មភាពវារីវប្បកម្ម និងតាមដានការបញ្ចេញកាកសំណល់របស់កសិដ្ឋានវារីវប្បកម្ម
- គ្រប់គ្រងការនាំចូល នាំចេញវារីជាតសមុទ្រ ឧបករណ៍ សម្ភារ ថ្នាំព្យាបាល និងសារធាតុគីមី ដែលពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ
- លើកទឹកចិត្តដល់ការវិនិយោគវិស័យឯកជន ដើម្បីជំរុញដល់ការអភិវឌ្ឍវារីវប្បកម្មសមុទ្រ
- បង្កើនផលិតកម្មពូជប្រភេទវារីជាតជិតផុតពូជ តាមរយៈការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកទេសវារីវប្បកម្ម
- ពិនិត្យសំណុំបែបបទស្នើសុំធ្វើវារីវប្បកម្ម និងតាមដានការបញ្ចេញកាកសំណល់របស់កសិដ្ឋានវារីវប្បកម្ម
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

៤.៤. ការិយាល័យស្រះជម្រកត្រីសហគមន៍៖

- រៀបចំផែនការសកម្មភាព និងលិខិតបទដ្ឋានសម្រាប់គ្រប់គ្រង និងអភិវឌ្ឍស្រះជម្រកត្រីសហគមន៍
- សិក្សាស្រាវជ្រាវកេកន្លែង ដែលមានសក្តានុពលសម្រាប់ពង្រីកតំបន់អភិវឌ្ឍស្រះជម្រកត្រីសហគមន៍
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាសម្រាប់គ្រប់គ្រង និងអភិវឌ្ឍស្រះជម្រកត្រីសហគមន៍
- រៀបចំបង្កើតទិន្នន័យ និងគ្រប់គ្រងការអភិវឌ្ឍន៍ស្រះជម្រកត្រីសហគមន៍
- រៀបចំទិន្នន័យ ឯកសារបណ្តុះបណ្តាលពីការបង្កើត និងគ្រប់គ្រងការអភិវឌ្ឍស្រះជម្រកត្រីសហគមន៍ និងលទ្ធផលស្រាវជ្រាវសម្រាប់អភិវឌ្ឍស្រះជម្រកត្រី
- បណ្តុះបណ្តាល និងផ្សព្វផ្សាយ រៀបចំបង្កើត និងគ្រប់គ្រងការអភិវឌ្ឍស្រះជម្រកត្រីសហគមន៍
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ។

៤.៥. ការិយាល័យគ្រប់គ្រងជំងឺ និងសុខភាពវារីសត្វ៖

- រៀបចំផែនការសកម្មភាព សម្រាប់គ្រប់គ្រងជំងឺ និងអភិវឌ្ឍបច្ចេកទេស គ្រប់គ្រងសុខភាពវារីសត្វ
- សិក្សាស្រាវជ្រាវអំពីវិធីសាស្ត្រការពារ ព្យាបាល និងគ្រប់គ្រងប្រភេទជំងឺវារីសត្វ

- តាមដាននិងពិនិត្យមើលហានិភ័យនៃជំងឺ ការរាតត្បាតលើវារិសត្វ វិធានការទប់ស្កាត់ និងដំណោះស្រាយជាបន្ទាន់
- រៀបចំឯកសារ និងបណ្តុះបណ្តុះបណ្តាលបច្ចេកទេស និងអភិវឌ្ឍទិន្នន័យគ្រប់គ្រងប្រភេទជំងឺវារិសត្វ វិធីសាស្ត្រ បង្ការ ការពារ គ្រប់គ្រង និងព្យាបាល
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកទេសធ្វើរោគវិនិច្ឆ័យជំងឺវារិសត្វ
- រៀបចំនិងផ្ញើរបាយការណ៍ទាក់ទងនឹងជំងឺវារិសត្វជូនអង្គការសុខភាពសត្វពិភពលោកWorld Organization for Animal Health (OIE) តាមភាពចាំបាច់
- ផ្សព្វផ្សាយ ជូនដំណឹង ករណីបន្ទាន់ពាក់ព័ន្ធ នឹងការកើតជំងឺរាតត្បាតនៃវារិសត្វ
- គ្រប់គ្រងការនាំចូល នាំចេញវារិសត្វទឹកសាប ទឹកសមុទ្រ ឧបករណ៍ សម្ភារ ថ្នាំ និងសារធាតុគីមី សម្រាប់ការពារព្យាបាល និងគ្រប់គ្រងប្រភេទជំងឺ និងសុខភាពវារិសត្វ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ការិយាល័យសុខភាពវារិសត្វនៃនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ឱ្យ ។

**ប្រការ២._**

ក្រៅពីការកែសម្រួលប្រការ៤ខាងលើ ខ្លឹមសារទាំងឡាយនៃប្រកាសលេខ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីរពិសោធន៍ ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផលត្រូវរក្សាទុកជាធរមានដដែល។

**ប្រការ៣._**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលជលផល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ២រោច ខែ ប.សាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៥៣...ប្រក.កសក.ប ចុះថ្ងៃ ព្រហ. ២កើត ខែ អាសាឍ.....ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី.១៤.....ខែ.មិថុនា.... ឆ្នាំ២០១៨

## អង្គការលេខរបស់នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល

